**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ : ៩៨៨ អយក.បក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ជម្រាបជូន**

**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ:** ការផ្តល់ប្រាក់ឧបត្ថម្ភដល់បណ្ណារក្សដែលធ្វើការពីរវេននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។

**យោង:** - អនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការកម្រិតភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប និងប្រាក់កំរៃសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

- សេចក្តីណែនាំលេខ២៥៦ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ
- ស្តង់ដារបណ្ណាល័យបឋមសិក្សា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ សូមលោក លោកស្រីប្រធានជ្រាបថា ក្រសួងបានរៀបចំស្តង់ដារបណ្ណាល័យបឋមសិក្សា និងកំពុងបន្តជំរុញការអាននិងការសិក្សាស្រាវជ្រាវនៅតាមបណ្ណាល័យ នៃគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅសាធារណៈ ។

ដើម្បីឱ្យបណ្ណាល័យនៅតាមគ្រឹះស្ថានសិក្សាដែលបង្រៀនពីរវេនអាចដំណើរការទៅបានជាប្រចាំ ក្រសួង សូមធ្វើការណែនាំដូចខាងក្រោម៖

១.សាលាបឋមសិក្សា ត្រូវរៀបចំបណ្ណារក្សឱ្យបានសមស្របតាមស្តង់ដារបណ្ណាល័យបឋមសិក្សា។ ក្នុងករណីបណ្ណារក្សធ្វើការពីរវេន ត្រូវរៀបចំផ្តល់ប្រាក់ភារកិច្ចបន្ថែមជាគ្រូបង្រៀនពីរវេន។

២.សាលាមធ្យមសិក្សាចំណេះទូទៅ ត្រូវរៀបចំបណ្ណារក្សឱ្យបានសមស្របតាមនិយាម។ ក្នុងករណីបណ្ណារក្សធ្វើការពីរវេន ត្រូវរៀបចំផ្តល់ប្រាក់ភារកិច្ចបន្ថែមជារបបម៉ោងបន្ថែម។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រីប្រធានចាត់តាំងអនុវត្ត ចាប់ពីឆ្នាំសិក្សា២០១៣-២០១៤ ខាងមុខនេះ ឱ្យមានប្រសិទ្ធភាព។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣)៤២៧ ៣៥៦/២១៧ ២៥៣/៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

Scanned with CamScanner

សូមលោក លោកស្រីប្រធានទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ។

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-គ្រប់អង្គភាពក្រោមឱវាទទីស្តីការ

ក្រសួងអប់រំ យុវជន និងកីឡា

" ដើម្បីជូនជ្រាប "

-កាលប្បវត្តិ-ឯកសារ.នា.បុគ្គលិក

អ៊ឹម_សិទ្ធី

Scanned with CamScanner